# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អ្នកនាំពាក្យ គ.ជ.ប

លេខ : ០៥៤ គ.ជ.ប

ថ្ងៃព្រហស្បតិ៍ ១០កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលសវនាការជាសាធារណៈដោះស្រាយពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ខេត្តប៉ៃលិន និងខេត្តត្បូងឃ្មុំ

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្រុមជំនុំជម្រះ គ.ជ.ប ដែលមានសមាសភាព ៩រូប ដឹកនាំដោយ **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប និងជាប្រធានក្រុមជំនុំជម្រះ គ.ជ.ប បានបើកសវនាការជាសាធារណៈ ដើម្បីជំនុំជម្រះលើពាក្យបណ្តឹង/សំណុំរឿង ចំនួន៥ ដែលត្រូវបានប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តរួមមាន ខេត្តកំពង់ចាម ខេត្តប៉ៃលិន និងខេត្តត្បូងឃ្មុំ។

បណ្តឹងតវ៉ាទាំងនោះមានដូចខាងក្រោម៖

១. សំណុំរឿងលេខ ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ ដើមបណ្តឹងឈ្មោះ **លី ម៉េងហ័ង** ភេទប្រុស កើតថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៨២ ប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេច លេខ ០០១ គ.ប/ក.ច ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ដែលបានផាកពិន័យខ្លួនជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

២. សំណុំរឿងលេខ ០០២ ចុះថ្ងៃទី១៩ ខែកក្កដា ២០២៣ ដើមបណ្តឹងមេធាវីឈ្មោះ **ហេង វណ្ណបុត្រ** តំណាងឱ្យលោក **ហ៊ាន រចនា** កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៨០ ប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ដែលបានផាកពិន័យឈ្មោះ **ខឹម មុនីកុសល** ភេទប្រុស កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៣ ជាប្រាក់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល និង



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ដែលការសម្រេចនេះមិនទៅតាមការចង់បានរបស់កូនក្តី (**ហ៊ាន រចនា**) ដែលស្នើសុំឱ្យដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

៣. សំណុំរឿងលេខ ០០៣ ចុះថ្ងៃទី១៩ ខែកក្កដា ២០២៣ ដើមបណ្តឹងមេធាវីឈ្មោះ **ហេង វណ្ណបុត្រ** តំណាងឱ្យលោក **ហ៊ាន រចនា** កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៨០ ប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០២ គ.ប/ក.ច ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ដែលបានផាកពិន័យ ឈ្មោះ **ស៊ុន សុភា** ភេទស្រី កើតថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩៤ ជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ដែលការសម្រេចនេះមិនទៅតាមការចង់បានរបស់កូនក្តី (**ហ៊ាន រចនា**) ដែលស្នើសុំឱ្យដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

៤. សំណុំរឿងលេខ ០០៤ និងលេខ ០០៥ ចុះថ្ងៃទី២២ ខែកក្កដា ២០២៣

- ដើមបណ្តឹងឈ្មោះ **យ៉ាន សុឃឿន** ភេទប្រុស កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៨២ ជាគ្រូបង្រៀន ប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០១ គ.ប/ត.ឃ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ដែលបានផាកពិន័យខ្លួនជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ។
- ដើមបណ្តឹងឈ្មោះ **ទូច ជីវ៉ា** ភេទប្រុស កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧២ ជាមេធាវី ប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០១ គ.ប/ត.ឃ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ដែលបានផាកពិន័យឈ្មោះ **យ៉ាន សុឃឿន** ភេទប្រុស កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៨២ ជាប្រាក់ និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិបោះឆ្នោត មានលក្ខណៈធូរស្រាល។

បន្ទាប់ពីបានស្តាប់ការឆ្លើយបំភ្លឺរបស់ដើមបណ្តឹង និងមេធាវីតំណាងចុងចម្លើយ ក្រោយពីបានពិនិត្យភស្តុតាង និងក្រោយពីបានពិភាក្សាស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររួចមក ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប សម្រេច៖

១. តម្កល់សេចក្តីសម្រេចលេខ ០០១ គ.ប/ក.ច ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល។ សេចក្តី



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

សម្រេចលេខ ០០១ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខដើមបណ្តឹង និងមេធាវីតំណាងគូភាគី បើកផ្លូវប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

២. តម្កល់សេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចលេខ ០០២ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខមេធាវីតំណាងដើមបណ្តឹង និងកំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

៣. តម្កល់សេចក្តីសម្រេចលេខ ០០២ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចលេខ ០០៣ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខមេធាវីដើមបណ្តឹង និងកំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

៤. តម្កល់សេចក្តីសម្រេចលេខ ០០១ គ.ប/ត.ឃ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចលេខ ០០៤ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខដើមបណ្តឹង និងមេធាវីតំណាងចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

បណ្តឹងទាំងអស់ខាងលើនេះ ពាក់ព័ន្ធទៅនឹងការណែនាំ រារាំង ឬញុះញង់ប្រជាពលរដ្ឋមិនឱ្យទៅបោះឆ្នោត ឬឱ្យអ្នកបោះឆ្នោតគូសបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត ដែលជាអំពើល្មើសដូចមានចែងក្នុងមាត្រា ១៤២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh